**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារត្រៀមលើកទី១របស់ដើមចោទ

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..............................................

លេខទូរស័ព្ទ ៖ .......................................................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u> ៖** សំណើសុំដាក់ **ឯកសារត្រៀមលើកទី១ របស់ដើមចោទ**ដើម្បីឆ្លើយតប ចំពោះឯកសារចម្លើយរបស់ឈ្មោះ Y ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ។

**<u>យោង</u> ៖** -មាត្រា **១០១ កថាខណ្ឌទី ២**នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

## គ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលមានសរសេរនៅក្នុងឯកសារចម្លើយ[1]

**គ.១.** អង្គហេតុដែលមានសរសេរនៅក្នុងចំណុច "**ខ.២.**" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ថា បានទិញនំផ្លែឈើ ចំនួន ១០.០០០ កញ្ចប់ ក្នុងតម្លៃ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកពីចុងចម្លើយនៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១២ ហើយនៅក្នុងចំណោមនំចំនួន ១០.០០០ កញ្ចប់នោះ មាន ៥០០ កញ្ចប់ដែលខូច ហើយដើមចោទមិនទទួលស្គាល់ចំពោះអង្គហេតុក្រៅពីនេះ។

ចំពោះនំ ៥០០កញ្ចប់ដែលលើកឡើងខាងលើនេះ មិនមែនថា មិនអាចលក់ចេញបាននោះទេ ហើយតាមការពិតដើមចោទបានលក់អស់ហើយ ហេតុនេះ ដើមចោទគ្រាន់តែព្រមានមិនឲ្យដាក់របស់បែបនេះទៀតពេលក្រោយ ហើយមិនបានទាមទារសំណងពីចុងចម្លើយទេ។ ដើមចោទមិនបានទទួលការសងប្រាក់ទាក់ទងនឹងរឿងនំផ្លែឈើនេះពីចុងចម្លើយនោះទេ។

**គ.២.** ការអះអាងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានសរសេរនៅក្នុងចំណុច "**គ.១**" នៃឯកសារចម្លើយ ៖ ដើមចោទមានវិវាទ [2]។

**គ.៣.** ការអះអាងអំពីការទូទាត់ដែលមានសរសេរនៅក្នុងចំណុច "**គ.២**" នៃ ឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ថា ចុងចម្លើយបានលក់រថយន្តក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក មកឲ្យដើមចោទនៅថ្ងៃទី ៣១ ខែ

[1] ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម៖ ① មធ្យោបាយតទល់ ឬ ការពារខ្លួន និង ② សេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០១ កថាខណ្ឌទី ២)។

[2] អង្គហេតុចម្បងស្តីអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺ ① ពេលដែលសិទ្ធិលើបំណុលអាចអនុវត្តបាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨១) ② អំឡុងពេលនៃអាជ្ញាយុកាលបានកន្លងផុតគិតចាប់ពីពេលនោះ (ក្រមរដ្ឋប្បវេណី មាត្រា៤៨២) ③ ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៦ កថាខណ្ឌទី ១) ។ នៅក្នុងរឿងក្តីនេះ ចំពោះចំណុចទាំងនេះ ចំណុចទី ① គូភាគីពុំមានវិវាទទេ រីឯចំណុចទី ② និងចំណុចទី ③ គឺជាអង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី ២ ) ដូច្នេះហើយ ចុងចម្លើយមិនចាំបាច់បញ្ជាក់ភស្តុតាងទៅលើ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។ ហេតុនេះ ដើមចោទ ក៏មិនចាំបាច់ទទួលស្គាល់ ឬ មិនទទួលស្គាល់ដែរ ប៉ុន្តែ ដើមចោទបានគិតថា ចង់បដិសេធនូវ ការសម្រេចបាននូវអាជ្ញាយុកាលដែលជា អានុភាពគតិយុត្ត។ ក្នុងករណីបែបនេះ គួរតែសរសេរថា "មានវិវាទ" ទើបប្រសើរ។

តុលា ឆ្នាំ ២០១៣ ហើយចុងចម្លើយបានប្រគល់រថយន្តនោះមកឲ្យដើមចោទនៅថ្ងៃដដែល ហើយដើមចោទមិនទទួលស្គាល់អង្គហេតុផ្សេងក្រៅពីនេះ ។

ដើមចោទបានបង់ប្រាក់ថ្លៃទិញរថយន្តឲ្យទៅចុងចម្លើយដូចក្នុងចំណុច "**ខ.២.**" នៃដែលបានសរសេរខាងក្រោម ។

## ខ. អង្គហេតុស្ដីពីការតវ៉ាតប

### ខ.១. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល[3] (ចំពោះការតវ៉ាអំពីការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល[4])

នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដើមចោទបានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកដែលជាការសងប្រាក់កម្ចីក្នុងរឿងក្ដីនេះពីចុងចម្លើយ។ នៅក្នុងលិខិតប្រគល់ ទទួលប្រាក់ដែលដើមចោទបានសរសេរ និងចេញឲ្យចុងចម្លើយ បានសរសេរអំពីខ្លឹមសារថា បានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ជាការសងប្រាក់កម្ចីនៃរឿងក្ដីនេះ **(ភស្តុតាង $X_3$)**។

ដោយសារតែចុងចម្លើយបានសងប្រាក់មួយផ្នែកនៃប្រាក់កម្ចីក្នុងរឿងក្ដីនេះ ដូច្នេះ នាំឲ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានផ្អាក។

### ខ.២. ការសង[5] (ចំពោះការតវ៉ាអំពីការទូទាត់)

ដើមចោទបានបង់ប្រាក់ចំនួន ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ជាថ្លៃលក់ទិញរថយន្តឲ្យទៅចុងចម្លើយនៅអំឡុងខែធ្នូ ឆ្នាំ២០១៣។

---

[3] ដើមចោទអាចអះអាងអំពីការសងមួយផ្នែក ធ្វើជាមូលហេតុនៃការផ្អាកអាជ្ញាយុកាលតាមផ្លូវច្បាប់បាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ កថាខណ្ឌទី ៣)។

[4] នៅពេលអះអាងអំពីការតវ៉ាតប យើងត្រូវបង្ហាញឲ្យច្បាស់ថាជាការតវ៉ាតបចំពោះការតវ៉ាមួយណា។

[5] អង្គហេតុចម្បងនៃការសងមាន ① មានការផ្ដល់តាវកាលិកផ្អែកតាមខ្លឹមសារនៃកាតព្វកិច្ចពីកូនបំណុលទៅម្ចាស់បំណុល (សូមយោងមាត្រា៤៩០ នៃក្រមរដ្ឋប្បវេណី) និង ② ទំនាក់ទំនងនៃតាវកាលិកជាមួយសិទ្ធិលើបំណុល។ ជាក់ស្ដែងត្រូវបង្ហាញថា ៖ ① គឺ "បានប្រគល់ប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក និង ② តើប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនេះ ត្រូវបានប្រគល់ដើម្បីអ្វី? គឺចាំបាច់ត្រូវសរសេរថា "ជាថ្លៃលក់ទិញរថយន្ត" ។

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១៥

**អ្នកតំណាងដោយអាណត្តិ**

P

"**ចំណុចដែលត្រូវប្រុងប្រយ័ត្ន**"

នៅក្នុងឯកសារត្រៀមលើកទី១ របស់ដើមចោទ ដើមចោទបានអះអាងនូវការតវ៉ាតបចំពោះការតវ៉ាដែលចុងចម្លើយបានអះអាងនៅក្នុងឯកសារចម្លើយ។ ហេតុនេះ ច្បាស់ជាត្រូវដាក់ឯកសារត្រៀមដើម្បីឲ្យចុងចម្លើយធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ ឬ ការធ្វើការតវ៉ា (ឯកសារត្រៀមលើកទី ១ របស់ចុងម្លើយ) ជាក់ជាមិនខាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០១ កថាខណ្ឌទី ២) ។ ប៉ុន្តែ តាមរយៈឯកសារចម្លើយនៅក្នុងរឿងក្តីនេះ ចុងចម្លើយបានអះអាងរួចហើយថា ការសង ១.០០០ ដុល្លារមេរិក គឺជាការសងចំពោះកាតព្វកិច្ចផ្សេង ហើយមិនមានការសងចំពោះប្រាក់ថ្លៃលក់ទិញទេ ហេតុនេះ គឺបង្ហាញឲ្យឃើញច្បាស់ថា ចុងចម្លើយមានវិវាទទៅលើគ្រប់ចំណុចដែលដើមចោទអះអាងនៅក្នុងការតវ៉ាតប។ ដូច្នេះទោះបីជាចុងចម្លើយមិនដាក់ឯកសារត្រៀមលើកទី ១ ក៏ដោយ ក៏តុលាការអាចធ្វើការសម្រេចបានថា ចុងចម្លើយមានវិវាទចំពោះការតវ៉ាតបរបស់ដើមចោទ ហេតុនេះ គឺមិនមានការសារភាពទេ (យោងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៦ កថាខណ្ឌទី ១)។